# ការសម្ភាសន៍របស់អ្នកមីង កង ណារិន

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ កង ណារិន

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ កង ណារិន</u>

សង្ខេបៈ អ្នកមីង កង ណារិន គាត់រស់នៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ គាត់ជាក្មេងកំព្រាឪពុក ដោយសារឪពុកគាត់មានប្រពន្ធចុង ហើយបានចាកចេញចោលម្តាយរបស់គាត់។ គាត់មានជីវិតដែលលំបាកតាំងក្មេងរហូតមកដល់ចាស់។ គាត់បានដើរស៊ីឈ្នួលដកស្ទូងជាមួយម្តាយរបស់គាត់តាំងពីគាត់នៅតូចរហូតមកដល់សព្វថ្ងៃគាត់នៅតែស៊ីឈ្នួលគេដោយដើរបោកខោអាវ អោយគេដើម្បីបានកំរៃតិចតួចចិញ្ចឹមជីវិត។ គាត់មានកូនបួននាក់តែគាត់នឹងកូនមិនសូវជាមាន ពេលវេលាជាមួយគ្នាប៉ុន្មានទេ ព្រោះដោយសារជីវភាពកូនគាត់បានចាកចេញពីគាត់ដើរស៊ីឈ្នួលគេ។ធ្វើឡើងនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០១៨។

កៈ អញ្ចឹង ជំរាបសួរអ្នកមីង ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវិប្រវត្តិផ្ទាល់ខ្លួនរបស់ ប្រជាជនកម្ពុជា ដែលធ្វើឡើងដោយសាកលវិទ្យាល័យ BYU នៅសហរដ្ឋអាមេរិច ដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ ក្រោយរបស់ពួកគាត់ ស្គាល់ពីប្រវត្តិរបស់ដូនតានិងឪពុកម្តាយ។ ហើយការសំភាសន៍នេះយើងធ្វើ នៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០១៨ ហើយយើងធ្វើនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយសំរាប់ការសំភាសន៍នេះ យើងនឹងថតសំលេង និងថតរូបភាពរបស់អ្នកមីង ហើយផ្ញើរទៅកាន់ សកលវិទ្យាល័យ BYU នៅសហរដ្ឋអាមេរិចដើម្បីគាត់អាចយកសំលេងនឹងរូបភាពរបស់អ្នកមីង ដាក់នៅលើ Website របស់សកលវិទ្យាល័យ។ អញ្ចឹង តើអ្នកមីងយល់ព្រម អោយពួកយើងយក រូបភាពនិងសំលេងរបស់អ្នកមីងដើម្បីដាក់នៅលើ Websites សកលវិទ្យាល័យ BYU នៅសហរដ្ឋ អាមេរិចដែរឬទេអ្នកមីង?

ខៈ ចាំ! ខ្ញុំព្រមលោកក្មួយ។

ក៖ អញ្ចឹង អរគុណអ្នកមីង ដែលយល់ព្រមអោយយើងយករូបភាពនឹងសំលេងរបស់អ្នកមីងដាក់នៅ លើ Website របស់សកលវិទ្យាល័យ ណាអ្នកមីង។ អញ្ចឹងដំបូង តើអ្នកមីងមានឈ្មោះពេញអ្វីដែរ អ្នកមីង?

ខ៖ ចាំ! ខ្ញុំឈ្មោះ កង ណារិន។

ក៖ ឈ្មោះ កង ណារិន ឬអ្នកមីង?

ខ៖ ចាំ!

ក៖ អញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេអ្នកមីង?

ខ៖ ឈ្មោះហៅក្រៅថា ណារិន។

ក៖ ណារិនហ៎ អ្នកមីង។ ហើយអញ្ចឹង នៅពេលក្មេងៗ តើគេហៅឈ្មោះរបស់អ្នកមីងថាម៉េចដែរ?

ខ៖ ហៅថា ណារិន។

ក៖ ហៅណារិន អ្នកមីង។ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានហើយ អ្នកមីង?

ខ៖ ខ្ញុំមានអាយុហាសិបប្រាំបួនឆ្នាំ។

ក៖ ហាសិបប្រាំបួនឆ្នាំ ឬអ្នកមីង?

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់អ្នកមីងទេ?

ខ៖ ខ្ញុំកើតឆ្នាំ ជូត។

ក៖ អញ្ចឹងមានន័យថា អ្នកមីងកើតនៅឆ្នាំខ្មែរគឺឆ្នាំជូត។ ហើយចុះអ្នកមីងមាននៅចាំឆ្នាំបារាំងទេ?

ខ៖ នៅឆ្នាំបារាំង ខ្ញុំអត់ចាំទេ។

កៈ អ្នកមីងមានអាយុហាសិបប្រាំបួនឆ្នាំ។
អញ្ចឹងសំរាប់អ្នកមីងប្រហែលជាកើតនៅក្នុងឆ្នាំមួយពាន់ ប្រាំបួនរយហាសិបប្រាំបួន។
ហ្នឹងហើយ! តើអ្នកមីងបានកើតនៅខេត្តណាដែរ អ្នកមីង?

ខៈ ខ្ញុំកើតនៅខេត្តត្បូងឃ្មុំនឹងម៉ង។

កៈ អញ្ចឹងកើតនៅខេត្តត្បូងឃ្មុំនឹងតែម្តង។ តើអ្នកមីងមាននៅចាំឈ្មោះភូមិ ឃុំ ស្រុក
ដែលអ្នកមីងបានកើតទេ?

ខៈ ខ្ញុំនៅចាំ ខ្ញុំកើតនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ហើយឥឡូវគេដាក់ខេត្តត្បូងឃ្មុំ។

កៈ បាទ បាទ! ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំកំព្រាតែម្នាក់ឯងទេ។

កៈ អូ! អ្នកមីងមានតែម្នាក់ឯងទេ។ ហើយអញ្ចឹង សំរាប់អ្នកមីង
តើឪពុករបស់អ្នកមីងមានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំឈ្មោះ យ៉ែម។

កៈ ហើយអ្នកមីងមាននៅចាំត្រកូលរបស់គាត់ទេ?

ខៈ ខ្ញុំអត់ចាំទេ ព្រោះខ្ញុំបែកឪពុកកំព្រាតាំងពីតូចក្រហមរងាលមក។

កៈ អូ! អ្នកមីងកំព្រាឪពុកហ៎! ហើយអញ្ចឹង អ្នកមីងដឹងថាគាត់បានកើតនៅឆ្នាំណាទេ?

ខៈ ខ្ញុំអត់ចាំផង។

កៈ ហើយអញ្ចឹង អ្នកមីងមានដឹងទេថា ពេលឪពុករបស់អ្នកមីងបានស្លាប់
គាត់មានអាយុប៉ុន្មានទេ?

ខៈ គាត់អត់ស្លាប់ រាល់ថ្ងៃគាត់នៅរស់តើ។

កៈ អូ! គាត់នៅរស់ទេ!

ខៈ គ្រាន់តែគាត់មានប្រពន្ធចុង បែកពីខ្ញុំតាំងពីតូចមកហើយ។

កៈ បាទ បាទ!!

ខៈ បានន័យថាអត់មានទាក់ទងគ្នា ពាក់ព័ន្ធគ្នាទេ។

កៈ ហើយសំរាប់សព្វថ្ងៃនេះ សំរាប់ឪពុកអ្នកមីង តើគាត់មានអាយុប៉ុន្មានហើយ អ្នកមីង?

ខៈ គាត់មានអាយុប៉ែតសិបប្រាំពីរឆ្នាំ។

កៈ អាយុគាត់ប៉ែតសិបប្រាំពីរឆ្នាំហើយ។ ហើយអ្នកមីងមាននៅចាំថា
គាត់បានកើតនៅឆ្នាំណាទេ?

ខៈ ខ្ញុំអត់ចាំទេ។

កៈ ហើយចុះសំរាប់ឪពុករបស់អ្នកមីង គាត់កើតឆ្នាំខ្មែរឆ្នាំអីដែរអ្នកមីង?

ខៈ ខ្ញុំអត់ដឹងដែលនឹង ព្រោះអីបែកខ្ញុំតាំងពីខ្ញុំនៅបីទទឹងមក។

កៈ អត់ដឹងទេអ្នកមីងន៎!

ខៈ អត់បានរួមរស់នៅជាមួយឪពុកពីតូចមកផង។

កៈ ហើយអញ្ចឹង! តើម្ដាយរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំ គាត់ឈ្មោះ កង អ៊ីម។

កៈ កង អ៊ីម ឬអ្នកមីង?

ខៈ ចា៎!

កៈ ហើយសំរាប់សព្វថ្ងៃ តើគាត់មានអាយុប៉ុន្មានហើយអ្នកមីង?

ខៈ សព្វថ្ងៃគាត់ស្លាប់បាត់ហើយ បើនៅដល់ឥឡូវគាត់មានអាយុហុកសិបឆ្នាំ។

កៈ អញ្ចឹង! តើម្ដាយរបស់អ្នកមីងគាត់កើតនៅពេលណាដែរ អ្នកមីង?

ខៈ ចាំតែអាយុគាត់ កាលគាត់ស្លាប់មានអាយុហាសិបប្រាំបួនឆ្នាំ។

កៈ ស្លាប់នៅអាយុហាសិបប្រាំបួនឆ្នាំ។ ហើយតើគាត់បានស្លាប់នៅឆ្នាំណាដែរអ្នកមីង?

ខៈ គាត់ស្លាប់អស់រយៈពេលម្ភៃឆ្នាំហើយ។

កៈ គាត់ស្លាប់រយៈម្ភៃឆ្នាំហើយ ន៎អ្នកមីង។ ហើយ តើគាត់កើតឆ្នាំខ្មែរ ឆ្នាំអី អ្នកមីងដឹងទេ?

ខៈ គាត់កើតឆ្នាំម្សាញ់ ចា៎!

កៈ ម្ដាយរបស់អ្នកមីងកើតក្នុងឆ្នាំម្សាញ់។ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់អ្នកមីង តើគាត់ប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមជីវិតដែរអ្នកមីង?

ខៈ គាត់ជាកសិករ។

កៈ កសិករហ៎! គាត់ធ្វើស្រែចំការ ឬអ្នកមីង?

ខៈ ពីមុនគាត់ធ្វើស្រែ ប៉ុន្តែបច្ចុប្បន្នឥឡូវអត់មានទេ ដីអីគេយកអស់ហើយ។

កៈ ហើយអញ្ចឹង! តើអ្នកមីងធ្លាប់ដឹងពីជីវិតរបស់ពួកគាត់ កាលគាត់នៅក្មេងៗទេអ្នកមីង?

ខៈ កាលគាត់នៅក្មេងៗគាត់គ្រាន់តែធ្វើស្រែ ធ្វើចំការជាមួយយាយខ្ញុំអីចឹង។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខៈ ឈ្មោះ តាកង យាយប៉ិន។

កៈ តាកង យាយប៉ិន។ ហើយសព្វថ្ងៃនេះ ពួកគាត់ស្លាប់អស់ហើយអ្នកមីង?

ខៈ ចាំ! គាត់ស្លាប់យូរហើយ។

កៈ ហើយអញ្ចឹង! សំរាប់ជីដូនជីតាខាងឪពុករបស់អ្នកមីង
គាត់កើតនៅពេលណាអ្នកមីងដឹងទេ?

ខៈ អត់ចាំផង។

កៈ ហើយសំរាប់ជីដូនជីតាខាងឪពុករបស់អ្នកមីង គាត់កើតឆ្នាំខ្មែរឆ្នាំអី អ្នកមីងនៅចាំទេ?

ខៈ អត់ចាំទេ។

កៈ ហើយតើពួកគាត់ស្លាប់នៅពេលណា អ្នកមីងចាំទេ?

ខៈ អត់ដឹងទេ តាំងពីជំនាន់ពលពតមកម្លេះ។

កៈ អញ្ចឹងមានន័យថាគាត់ស្លាប់តាំងពីជំនាន់ពលពត។
ហើយអញ្ចឹងអ្នកមីងមាននៅចាំឈ្មោះ ជីដូនជីតាខាងម្ដាយទេអ្នកមីង?

ខៈ ជីដូនជីតាខាងម្ដាយនឹងឈ្មោះ តាកង យាយប៉ិន។

កៈ ហើយចុះជីដូនជីតាខាងឪពុកវិញ ឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំអត់ចាំទេ ព្រោះគេវាយចោលអស់ហើយកាលនៅជំនាន់ពលពត ព្រោះកាលនឹងខ្ញុំនៅតូចៗ។

ក៖ អញ្ចឹង សំរាប់តាកង យាយប៊ិននឹង គាត់ជាជីដូនជីតាខាងម្ដាយទេ មិនមែនជីដូនជីតាខាងឪពុកទេ។ ជីដូនជីតាខាងឪពុកអ្នកមីងបានស្លាប់ក្នុងសម័យពលពតអ្នកហើយអ្នកមីងអត់បានស្គាល់ទេ។ តើអ្នកមីងមានធ្លាប់ដឹងរឿងរបស់ជីដូនជីតារបស់អ្នកមីងទេ?

ខ៖ រឿងរបស់ជីដូនជីតានឹងខ្ញុំមិនសូវជាដឹងទេ ព្រោះខ្ញុំនៅក្មេងពេក។

ក៖ អញ្ចឹងអ្នកមីងមិនសូវដឹងទេ។ ហើយអញ្ចឹងសំរាប់ពេលអ្នកមីងកើតមក តើជីដូនជីតារបស់អ្នកមីងគាត់នៅរស់ ឬគាត់ស្លាប់ហើយ?

ខ៖ កាលខ្ញុំកើតមកគាត់នៅរស់ទេ តែដល់ពេលជំនាន់ពលពត ជំនាន់គេទំលាក់គ្រាប់បែក ជំនាន់រដ្ឋប្រហារនឹងទេ គាត់ស្លាប់អស់ហើយ។

ក៖ អញ្ចឹងគាត់ស្លាប់ក្នុងជំនាន់សង្គ្រាមអស់ហើយអ្នកមីង។ អញ្ចឹងកាលដែលពួកគាត់ស្លាប់នឹង តើអ្នកមីងមានអាយុប្រហែលប៉ុន្មានដែរ?

ខ៖ កាលដែលពួកគាត់ស្លាប់នឹង ខ្ញុំអាយុប្រហែលជាដប់ឆ្នាំប៉ុណ្ណឹង។

ក៖ អូ! អ្នកមីងអាយុប្រហែលជាដប់ឆ្នាំន៎អ្នកមីង។ ហើយតើពួកគាត់បានស្លាប់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ពួកគាត់បានស្លាប់នៅនឹងស្រុកកំណើតនឹងម៉ង។

ក៖ គាត់ស្លាប់នៅស្រុកកំណើតយើង ត្បូងឃ្មុំនឹងមែនទេអ្នកមីង?

ខ៖ ចា៎! គាត់ស្លាប់នៅនឹងភូមិយើងនឹងតែម្ដង។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង ហើយនឹងក្រុមគ្រួសាររបស់អ្នកមីងបានរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ខ្ញុំបានរស់នៅក្នុងខេត្តនេះតាំងពីខ្ញុំកើតមកម្លេះ។

ក៖ ចឹងមានន័យថា អ្នកមីងរស់នៅខេត្តនេះតាំងពីអ្នកមីងកើតតែម្ដងន៎!

ខ៖ ហ្នឹងហើយ! ដឹងក្ដីមករស់នៅខេត្តនឹងតែម្ដង។

កៈ ហើយអញ្ចឹង! តើអ្នកមីងមានសាច់ញាត្តិដទៃទៀតដែលរស់នៅក្រៅប្រទេសខ្មែរទេ អ្នកមីង?

ខៈ ខ្ញុំគ្មានផង មានតែជីតាមួយប្អូនយាយខ្ញុំ គាត់រស់នៅអូស្រ្តាលី ប៉ុន្តែគាត់បានស្លាប់បាត់ហើយ។

កៈ ចឹងមានជីតាមួយនៅអូស្រ្តាលី តែគាត់បានស្លាប់បាត់ហើយឬអ្នកមីង?

ខៈ ហ្នឹងហើយ! គាត់ស្លាប់បាត់ហើយ គាត់មិនដែលតេមក ហើយមិនដែលបានទាក់ទងមកទេ។

កៈ ហើយអញ្ចឹង! តើស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ស្វាមីរបស់ខ្ញុំឈ្មោះ ស្រ៊ីម ម៉ាប់។

កៈ ស្រ៊ីម ម៉ាប់។ ហើយអញ្ចឹង តើអ្នកមីងបានរៀបការជាមួយគាត់នៅពេលណាដែរ?

ខៈ កាលដែលខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំ ខ្ញុំមានអាយុម្ភៃឆ្នាំ។

កៈ អូ! អញ្ចឹងពេលដែលអ្នកមីងបានរៀបការ អ្នកមីងមានអាយុម្ភៃឆ្នាំ។ ហើយអញ្ចឹងអ្នកមីងមាននៅចាំទេថា អ្នកមីងបានរៀបការនៅឆ្នាំណាទេ?

ខៈ មិនចាំដែលនឹង ភ្លេចអស់ហើយ វាយូរហើយនឹង។ អូ! នៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែតមួយ។

កៈ អញ្ចឹងអ្នកមីងបានរៀបការជាមួយលោកពូនៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែតមួយ។ ពេលដែលអ្នកមីងរៀបការជាមួយលោកពូ តើអ្នកមីងមានអាយុប៉ុន្មានហើយ?

ខៈ ពេលខ្ញុំរៀបការជាមួយគាត់ ខ្ញុំមានអាយុម្ភៃឆ្នាំ។

កៈ ហើយអញ្ចឹង! សំរាប់អាពាហ៍ពិពាហ៍នឹង អ្នកមីងរៀបចំឡើងដោយខ្លួនឯង ឬមួយឪពុកម្តាយរបស់អ្នកមីងគាត់ជាអ្នករៀបចំអោយ?

ខៈ ម្តាយរបស់ខ្ញុំអ្នករៀបចំអោយ ប៉ុន្តែប្តីរបស់ខ្ញុំគាត់កំព្រាដែរ គាត់មានតែឪពុកចិញ្ចឹម។

កៈ អញ្ចឹងមានន័យថា ឪពុកចិញ្ចឹមគាត់ជាអ្នករៀបចំអោយ។ អញ្ចឹង! នៅពេលដែលរៀបចំនឹង មានដូចជាថ្លៃជំនួនទេអ្នកមីង?

ខៈ មានតើ។

កៈ អញ្ចឹង! តើការៀបការរបស់អ្នកមីងនឹង ថ្លៃជំនូនប៉ុន្មានដែរអ្នកមីង?

ខៈ កាលនោះធ្វើសែសិបប្រាំបីតុ។

កៈ ធ្វើសែសិបប្រាំបីតុ។ ថ្លៃជំនូន តម្លៃវាប្រហែលប៉ុន្មានដែរអ្នកមីង?

ខៈ តម្លៃដែលគេជូនមែន?

កៈ បាទ!

ខៈ តម្លៃដែលគេជូន ថ្លៃទឹកដោះ នៅលើគេទាំងអស់តែម្ដងក្នុងការរៀបការនឹង គេជូនហើយប្រាំតុ ផ្ដាច់។

កៈ អូ! កាលនឹងគេអត់គិតជាលុយទេ គេគិតអោយតុយើងវិញ ប្រាំតុន់មីងន់។ បាទ បាទ យល់!

អញ្ចឹងសំរាប់អ្នកមីង អ្នកមីងគិតថាជីវិតមុនអ្នកមីងរៀបការ និងជីវិតក្រោយអ្នកមីងរៀបការ មានភាពខុសគ្នាទេ?

ខៈ ជីវិតមុនរៀបការ និងជីវិតក្រោយរៀបការមានភាពខុសគ្នាឆ្ងាយ។

កៈ អញ្ចឹង តើមានភាពខុសគ្នាអ្វីខ្លះទៅអ្នកមីង?

ខៈ ខុសគ្នាត្រង់ថា ខ្ញុំបានគ្រួសារទៅ ខ្ញុំរកស៊ីបែកម៉ែបែកឪទៅខ្ញុំកំសត់កំក្រខ្លាំងណាស់។

កៈ ហើយអញ្ចឹង សំរាប់ចំណងអាពាហ៍ពិពាហ៍អ្នកមីងមានកូនប៉ុន្មាននាក់ដែរអ្នកមីង?

ខៈ ខ្ញុំមានកូនទាំងអស់បួននាក់។

កៈ តើអ្នកមីងមានកូនប្រុសប៉ុន្មាន ស្រីប៉ុន្មាន អ្នកមីង?

ខៈ ខ្ញុំមានកូនប្រុសមួយ ហើយនឹងស្រីបីនាក់។

កៈ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះទាំងបួននាក់របស់អ្នកមីងបានទេ?

ខៈ ទីមួយឈ្មោះ ស្រ៊ុម ស្រា, ទីពីរឈ្មោះ ស្រ៊ុម លីណា, ទីបីឈ្មោះ ស្រ៊ុម សុម៉ាលី និងទីបួនឈ្មោះ ស្រ៊ុម ពៅ។

កៈ ហើយសំរាប់កូនច្បងរបស់អ្នកមីង សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានហើយ?

ខៈ កូនច្បងគេរបស់ខ្ញុំមានអាយុជិតសែសិបឆ្នាំហើយ ឆ្នាំកុរ។

ក៖ គាត់កើតឆ្នាំកុរន់! ហើយចុះកូនទីពីររបស់អ្នកមីង គាត់មានអាយុប៉ុន្មានហើយ?

ខ៖ កូនទី២របស់ខ្ញុំគាត់មានអាយុសាមសិបឆ្នាំហើយ គាត់កើតឆ្នាំឆ្លូវ។

ក៖ គាត់មានអាយុសាមសិបឆ្នាំ កើតឆ្នាំឆ្លូវ។ ហើយចុះកូនទីបីរបស់អ្នកមីងវិញ

មានអាយុប៉ុន្មនហើយ?

ខ៖ កូនទីបីកើតឆ្នាំវក។

ក៖ កើតឆ្នាំវក ន់អ្នកមីង។ ហើយចុះកូនទីបួនវិញអ្នកមីង?

ខ៖ កូនទីបួនកើតឆ្នាំឆ្លូវដែរ ៣គេ។

ក៖ កើតឆ្នាំឆ្លូវដែរ។ ហើយសំរាប់អ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយកូនៗទាំងបួនអ្នកនឹង
អ្នកមីង?

ខ៖ សំរាប់ខ្ញុំហ៎! កូនបែកមានគ្រួសារអស់ទៅ ខ្ញុំរាល់ថ្ងៃដើរបោកខោអាវអោយគេ។

ក៖ ហើយអ្នកមីងធ្លាប់មានអនុស្សាវរីយ៍ល្អៗអីជាមួយកូនទេអ្នកមីង?

ខ៖ គ្មានអនុស្សាវរីយ៍ល្អអីជាមួយកូនទេ បើកូនដឹងក្តីឡើង
កូនស៊ីឈ្នួលគេបែកអស់ហើយ។

ក៖ ដោយសារតែជីវភាពយើងពិបាកពេកន់អ្នកមីង។

ខ៖ កូន៣គេនឹងទៅនៅជាមួយគេតាំងពីអាយុដប់បួនឆ្នាំមកម្លេះ។

ក៖ អូ! កូន៣គេ ទៅនៅជាមួយគេតាំងពីអាយុដប់បួនឆ្នាំ?

ខ៖ ចា៎! ដោយសារយើងអត់ពេក អោយកូនទៅនៅជាមួយគេបានជួយយើងតិចតួច។

ក៖ អញ្ចឹង អ្នកមីងចេះអាន និងសរសេរអក្សរខ្មែរទេ អ្នកមីង?

ខ៖ ខ្ញុំអត់ចេះទេ កាលជំនាន់ពលពតអត់បានរៀនសូត្រអីផង គេអោយយើងធ្វើការរហូត។

ក៖ ហើយអញ្ចឹង អ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ?

ខ៖ អត់ចេះទេ។

ក៖ ហើយអញ្ចឹង អ្នកមីងធ្លាប់បានរៀននៅក្នុងសាលាទេ អ្នកមីង?

ខ៖ ខ្ញុំរៀនៗទៅ ជំនាន់ពលពតគេយកទៅនៅកងចល័តអត់បានរៀនសូត្រអី។

ក៖ ហើយអញ្ចឹង កាលអ្នកមីងរៀនហ្នឹង រៀនដល់ថ្នាក់ទីប៉ុន្មានដែរ អ្នកមីង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី២ តែគេយកទៅកងចល័តបាតហើយ លែងបានរៀនទៀត។

ក៖ ហើយអញ្ចឹង សាលាដែលអ្នកមីងបានរៀននឹង នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ខ្ញុំរៀននៅសាលាវាលកណ្ដៀង។

ក៖ អូ! អ្នកមីងបានរៀននៅសាលាវាលកណ្ដៀងហ៎!
ហើយអ្នកមីងចាំឈ្មោះសាលាវាលកណ្ដៀងនឹងទេ តើឈ្មោះសាលានឹងឈ្មោះអីដែរ?

ខ៖ សាលាវាលកណ្ដៀងនឹង ឈ្មោះសាលាវាលកណ្ដៀងនឹងម៉ង។

ក៖ អូ! សាលានឹងឈ្មោះសាលាវាលកណ្ដៀងតែម្ដងហ៎។ ហើយអញ្ចឹង
អ្នកមីងមានមិត្តភក្តិជិតស្និតដែលធំធាត់មកជាមួយគ្នាតាំងពីក្មេងមកទេ?

ខ៖ ខ្ញុំបើរាប់អានធម្មតាៗមាន តែបើជិតដិតម៉ង គ្មានទេ។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះ អ្នកមីងមានធ្វើស្រែចំការទេ អ្នកមីង?

ខ៖ រាល់ថ្ងៃនេះមីងអត់មានអីទាំងអស់ ដៃទទេតែម្ដង។

ក៖ ចឹងអត់មានទេអ្នកមីង។ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ
អ្នកមីងធ្វើអ្វីដើម្បីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខ៖ មីងដើរបោកខោអាវអោយគេ ហើយគេអោយលុយខ្លះមកដើម្បីផ្គត់ផ្គង់គ្រួសារ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង អ្នកមីងគិតថាជីវិតរបស់អ្នកមីង
តាំងពីក្មេងរហូតមកដល់ពេលនេះមានការផ្លាស់ប្ដូរទេ អ្នកមីង?

ខ៖ ជីវិតរបស់មីង គ្មានការផ្លាស់ប្ដូរទេ នៅតែដដែល។

ក៖ អញ្ចឹងនៅតែដដែលន៎ មីងន៎!
ហើយអញ្ចឹងតើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេអ្នកមីង?

ខ៖ ម្ហូបដែលចូលចិត្តហូបជាងគេនោះ គឺត្រីងៀត។

ក៖ អូ! អ្នកមីងចូលចិត្តហូបត្រីងៀត។ ហើយចុះសំរាប់ល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង ទាញព្រ័ត្រ លាក់កន្សែង បោះអង្គុញ តើមានល្បែងប្រជាប្រិយណាដែរអ្នកមីងចូលចិត្តលេងដែរឬទេ?

ខ៖ អត់មានល្បែងណាដែលចូលចិត្តលេងផង។

ក៖ ហើយអញ្ចឹង មានបទចម្រៀងណាខ្លះដែលអ្នកមីងចូលចិត្តស្តាប់ ហើយរៀនច្រៀងតាមតាំងពីក្មេងមកទេ អ្នកមីង?

ខ៖ ចូលចិត្តបទប្រពៃណីដូចជា រាំវង់ រាំក្បាច់អីនឹង។

ក៖ អូ! អញ្ចឹងអ្នកមីងចូលចិត្តចំរៀងបទរាំវង់ រាំក្បាច់ប្រពៃណីខ្មែរ។ ហើយអញ្ចឹង តើមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងដែលចេះលេងឧបករណ៍ភ្លេងទេ អ្នកមីង?

ខ៖ នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំគ្មាននរណាម្នាក់ចេះលេងភ្លេងទេ។

ក៖ អូ! ក្នុងគ្រួសារមិនអត់មានអ្នកចេះលេងទេន៎ អ្នកមីង។ ហើយអញ្ចឹង សំរាប់ផ្ទះរបស់អ្នកមីងកាលនៅពីក្មេងមានលក្ខណៈដូចម្តេចដែរអ្នកមីង?

ខ៖ ផ្ទះខ្ទមតូច មានជណ្តើរប្រាំពីរកាំ។

ក៖ អូ! ហើយផ្ទះនឹង អ្នកមីងធ្វើខ្លួនឯង ឬមួយអ្នកមីងបានជួលគេធ្វើ?

ខ៖ ផ្ទះណា?

ក៖ ផ្ទះដែលអ្នកមីងបានរស់នៅពីតូច?

ខ៖ ផ្ទះនឹងជាផ្ទះរបស់ម្តាយតាំងពីកំណើតតែម្តង។

ក៖ ហើយអញ្ចឹង ផ្ទះនឹងម្តាយរបស់អ្នកមីងគាត់ធ្វើដោយខ្លួនឯង ឬមួយគាត់ជួលគេ?

ខ៖ ផ្ទះនឹងគាត់ធ្វើដោយខ្លួនឯង។

ក៖ អូ! ផ្ទះនឹងគាត់ធ្វើដោយខ្លួនឯងហ៎!

ខ៖ តែផ្ទះនឹងអស់ពីម៉ែខ្ញុំទៅគេយកអស់ហើយ។

ក៖ ផ្ទះដែលម្តាយរបស់អ្នកមីងបានធ្វើនឹង បានធ្វើឡើងដោយសំភារៈអ្វីខ្លះ អ្នកមីង?

ខ៖ ផ្ទះនឹងធ្វើឡើងដោយសំភារៈឬស្សី សរសរកូនឈើតូចៗប៉ុនភ្លៅយើងនឹង ហើយប្រក់ស្លឹកត្នោត។

ក៖ ហើយអញ្ចឹង នរណាគេដែល ដែលបានបង្រៀនអោយគាត់ធ្វើផ្ទះមួយនឹង?

ខ៖ ផ្ទះនឹងគាត់ធ្វើខ្លួនគាត់ ដូចថាគាត់មេម៉ាយ តាំងពីខ្ញុំនៅក្រហមរងៀលមក គាត់ធ្វើអោយកូននៅតែម្តង។

ក៖ អូ! គាត់ចេះធ្វើវាដោយខ្លួនឯងន៎ មីងន៎!

ខ៖ ខ្ញុំក៏ធ្លាប់ឡើងប្រក់ដំបូលផ្ទះដោយខ្លួនឯងដែរនឹង។

ក៖ ហើយអញ្ចឹង អ្នកមីងមានដូចជាជំនាញដែលបន្តវេនពីក្រុមគ្រួសារអ្នកមីងដូចជា ជំនាញវេញវល្លិ៍ផ្តៅ ឬជំនាញក្នុងការធ្វើស្ករត្នោត?

ខ៖ ជំនាញដែលបន្តវេនពីគ្រួសារខ្ញុំអត់មានផង ព្រោះគ្រួសារខ្ញុំអត់មាននរណាចេះផង។

ក៖ តើអ្នកមីងធ្លាប់មានពេលដែលលំបាកជាងគេនៅក្នុងជីវិតរបស់អ្នកមីងទេ?

ខ៖ ពេលដែលលំបាកជាងគេក្នុងជីវិតរបស់ខ្ញុំគឺ ពេលដែលខ្ញុំដើរស៊ីឈ្នួលគេ ដកស្ទូងអីចឹងកាលនៅតូចជាមួយម្តាយ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីងបានឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែលអ្នកមីង?

ខ៖ កាលពីតូចនៅជំនាន់ពលពតទៅរែកដីរែកអីអោយគេ ហើយបន្ទាប់ពីជំនាន់ពលពតមក ដើរស៊ីឈ្នួលដកស្ទូងជាមួយម្តាយខ្ញុំប៉ុននឹង។

ក៖ ហើយអញ្ចឹង អ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗទេនៅក្នុងជីវិតទេ ដូចជាអាពាហ៍ពិពាហ៍កូន ឬបុណ្យទានអីចឹងណាអ្នកមីង?

ខ៖ មានរៀបអាពាហ៍ពិពាហ៍កូន។

ក៖ អញ្ចឹង សំរាប់អាពាហ៍ពិពាហ៍កូនរបស់អ្នកមីងនឹង តើអ្នកមីងមានអារម្មណ៍ដូចម្តេចដែរ អ្នកមីង?

ខ៖ ពេលកូនមានក្រុមគ្រួសារទៅដូចថាមានអារម្មណ៍រំភើបដែល ដោយគិតថាកូនមានទីពឹងពាក់។

ក៖ ហើយអញ្ចឹង សំរាប់ពេលដែលអ្នកមីងនៅក្មេង តើអ្នកមីងចង់ធ្វើអ្វីដែលពេលដែលអ្នកមីងធំឡើង?

ខ៖ គិតទៅតាំងពីតូចរហូតដល់ធំ គ្មានអីទីពឹងម៉ង
ដូចគ្មានសង្ឃឹមអីជាមុខរបរពិតប្រាកដអត់។

ក៖ អត់មានទេអ្នកមីង។ ហើយអញ្ចឹង បើអ្នកមីងចង់ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយ
តើអ្នកមីងនឹង ផ្តាំផ្ញើរអ្វីខ្លះទៅកាន់ពួកគេ អ្នកមីង?

ខ៖ ខ្ញុំគ្រាន់តែផ្តាំផ្ញើរអោយកូនចៅនឹងធ្វើអោយត្រឹមត្រូវ
កុំអោយខុសឆ្គងពីទំនៀមទំលាប់ប្រពៃណីយើងចឹងណា ធ្វើអោយបានល្អ
ហើយនឹងអោយកូនចៅខំរៀនសូត្រអោយមានចំណេះដឹងជ្រៅជ្រះ មានការងារល្អ
កុំអោយដើរស៊ីឈ្នួលគេទៀតពិបាកណាស់បានព្រឹកខ្វះល្ងាច។

ក៖ ហើយបើសិនជាអ្នកមីងចង់អោយពួកគាត់ជៀសវាង
តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះអ្នកមីង?

ខ៖ ខ្ញុំចង់អោយកូនចៅជៀសវាងពីភ្លើតភ្លើន ការដេលត្មេះគេ មើលងាយគេ
គ្រឿងញៀនជាដើម សូមអោយពួកគេជៀសអោយផុតចឹង។

ក៖ ហ្នឹងហើយ! អញ្ចឹងជាចុងក្រោយអ្នកមីង
ខ្ញុំសូមអរគុណអ្នកមីងដែលបានចំណាយពេលអោយខ្ញុំបានសំភាសន៍អ្នកមីងពីខ្សែជីវិតរបស់អ្នកមីង ហើយខ្ញុំសូមជូនពរអ្នកមីង សូមអោយអ្នកមីងមានសុភមង្គលនៅក្នុងក្រុមគ្រួសារ
មានសុខភាពល្អ មានកំលាំងមាំមួន
ហើយថាមុខរបររកស៊ីរបស់អ្នកមីងចេះតែរីកចំរើនទៅមុខរហូត
ហើយសូមអោយកូនចៅរបស់អ្នកមីងទាំងអស់គ្នាមានសុខភាពល្អ
ហើយថារបររកស៊ីរបស់ពួកគាត់រីកចំរើនទៅមុខ ដើម្បីពួកគាត់អាចជួយដល់អ្នកមីង
ហើយជួយ អោយជីវិតរបស់អ្នកមីងបានល្អប្រសើរជាង។
ហើយខ្ញុំសង្ឃឹមថាតាមរយៈការសម្ភាសន៍របស់យើង អំពីខ្សែជីវិតរបស់អ្នកមីង
នឹងជួយដល់កូនចៅជំនាន់ក្រោយរបស់អ្នកមីង
រៀនពីខ្សែជីវិតរបស់អ្នកមីងដើម្បីពួកគេអាចមានខ្សែជីវិតតស៊ូដូចជាអ្នកមីងដែរ។
អរគុណអ្នកមីងច្រើន។